# Vacancy Announcement

FTB
ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា
Foreign Trade Bank of Cambodia

## ដំណឹងជ្រើសរើសបុគ្គលិក

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា (FTB) គឺជាធនាគារពាណិជ្ជក្នុងស្រុកទី១ នៅកម្ពុជាដែលទទួលបានការទុកចិត្តចាប់តាំងពីឆ្នាំ១៩៧៩ ។ ធនាគារ FTB បានផ្តល់ជូនអតិថិជននូវសេវាហិរញ្ញវត្ថុប្រកបដោយភាពជឿទុកចិត្ត និងសុវត្ថិភាពខ្ពស់ក្នុងធុរកិច្ចរបស់ខ្លួន ។ ផ្អែកលើចក្ខុវិស័យ ជាធនាគារពាណិជ្ជដែលមានការពេញចិត្តជាងគេក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារ FTB ប្តេជ្ញាបន្តគាំទ្រធុរកិច្ចរបស់អតិថិជនឲ្យកាន់តែរីកចម្រើនលូតលាស់ និងផ្តល់ជូនគ្រប់បុគ្គលិកនូវឱកាសអាជីពការងារ ដែលមានស្ថិរភាពយូរអង្វែងផងដែរ ។ ធនាគារកំពុងបន្តពង្រីកនូវវិសាលភាពប្រតិបត្តិការរបស់ខ្លួន និងពង្រឹងសមត្ថភាពបុគ្គលិកដើម្បីជួយទ្រទ្រង់នូវការរីកចម្រើនប្រកបដោយចីរភាពយូរអង្វែង។ ទន្ទឹមនឹងការពង្រីកប្រតិបត្តិការនេះធនាគារយើងខ្ញុំ កំពុងស្វែងរកនូវបេក្ខភាពដែលមានគុណវុឌ្ឍិ និងឆន្ទៈខ្ពស់ ដើម្បីចូលរួមជាមួយធនាគារ FTB "**និយោជកដ៏ប្រសើរនិងឈានមុខ**" សម្រាប់មុខងារខាងក្រោម៖

## បុគ្គលិកផ្នែករដ្ឋបាលឥណទាន(ចំនួន 04 នាក់ បម្រើការនៅការិយាល័យកណ្តាល-ភ្នំពេញ)

រួមចំណែកបង្កើតទម្រង់កិច្ចសន្យាខ្ចីប្រាក់ និងទម្រង់ផ្សេងៗ ពាក់ព័ន្ធនឹងដំណើរការផ្តល់ឥណទាន ចងក្រងតារាងចំណាត់ថ្នាក់ វាយតម្លៃប្រភេទដី/ផ្ទះ សម្របសម្រួលដាក់បន្ទុកប្លង់ដី/ផ្ទះ ត្រួតពិនិត្យឡើងវិញពីការបំពេញលើគ្រប់ទម្រង់របស់ បុគ្គលិកឥណទាន ផ្ទៀងផ្ទាត់ឯកសារគាំទ្រ ស្នាមមេដៃ ត្រួតពិនិត្យ និងការវាយតម្លៃទ្រព្យធានា រៀបចំឯកសារឥណទានរបស់អតិថិជន ។

## កិច្ចការចម្បងៗ និងការទទួលខុសត្រូវ

- ចូលរួមចាត់ចែង បង្កើតទម្រង់ពាក្យសុំខ្ចីប្រាក់ ទម្រង់កិច្ចសន្យាខ្ចីប្រាក់ ទម្រង់ដាក់ទ្រព្យធានា និងទម្រង់ផ្សេងៗ ពាក់ព័ន្ធនឹងការ ផ្តល់ឥណទាន ព្រមទាំងធ្វើបច្ចុប្បន្នភាពជាប្រចាំ ទៅតាមវឌ្ឍនភាព និងធ្វើឱ្យកាន់តែងាយស្រួល ចៀសវាងហានិភ័យផ្សេងៗ ប្រកបដោយប្រសិទ្ធភាព ។
- ត្រួតពិនិត្យការបំពេញ ឬការបញ្ចូលព័ត៌មានក្នុងទម្រង់ខាងលើ របស់បុគ្គលិកឥណទាន ឱ្យបានគ្រប់ជ្រុងជ្រោយ លម្អិត នូវគ្រប់ទម្រង់ទាំងអស់ ផ្ទៀងផ្ទាត់ឯកសារគាំទ្រ ស្នាមមេដៃ និងកំណត់ហេតុអង្គប្រជុំរបស់គណៈកម្មការឥណទាន ឱ្យអនុលោមទៅតាមគោលនយោបាយឥណទានរបស់ធនាគារ ។
- ត្រួតពិនិត្យបន្ថែមទៅលើទ្រព្យធានា ការវាយតម្លៃ ទឹកប្រាក់ស្នើសុំខ្ចី និងទឹកប្រាក់អនុម័ត អត្រាការប្រាក់ រយៈពេលខ្ចី ត្រា និងហត្ថលេខា ថ្ងៃខែឆ្នាំអនុម័តឥណទាន ។
- រៀបចំឯកសារឥណទានរបស់អតិថិជននីមួយៗ ឱ្យបានត្រឹមត្រូវ គ្រប់គ្រាន់ រក្សាទុកដាក់ទៅតាមលក្ខណៈបច្ចេកទេស សុវត្ថិភាព ងាយស្រួលរកពេលមានតម្រូវការ ។
- ត្រួតពិនិត្យទ្រព្យធានា ប្រភេទជាអចលនទ្រព្យ និងចលនទ្រព្យគ្រប់ប្រភេទឥណទាន ជាវិញ្ញាបនបត្រ ប័ណ្ណសម្គាល់សិទ្ធិ ឬលិខិតផ្សេងៗដែលមានតម្លៃស្មើ ចុះ-លុបបន្ទុកបញ្ជីហ៊ីប៉ូតែក ឱ្យបានត្រឹមត្រូវ ។
- គ្រប់គ្រងសន្និធិសម្ភារៈប្រើប្រាស់ក្នុងការបំពេញការងារ និងតម្រូវការក្នុងនាយកដ្ឋាន ។
- ការងារផ្សេងៗទៀតទៅតាមការចាត់តាំងរបស់ថ្នាក់គ្រប់គ្រង ។

## លក្ខណសម្បត្តិ និងបទពិសោធន៍

- បរិញ្ញាបត្រ ផ្នែកធនាគារ ហិរញ្ញវត្ថុ ឬផ្នែកផ្សេងៗដែលពាក់ព័ន្ធ
- មានបទពិសោធន៍យ៉ាងតិច ១ឆ្នាំ ផ្នែករដ្ឋបាលឥណទាន ក្នុងវិស័យធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុ
- មានជំនាញ និងសមត្ថភាពក្នុងការប្រាស្រ័យទាក់ទងល្អជាមួយអតិថិជនបានគ្រប់កម្រិត
- មានការលើកទឹកចិត្ត និងជម្រុញដល់ក្រុមការងារឱ្យសម្រេចទៅដល់គោលដៅរួម
- មានភាពអត់ធ្មត់ មានការទទួលខុសត្រូវខ្ពស់ និងមានការយកចិត្តទុកដាក់ក្នុងការងារ
- ជំនាញក្នុងការទំនាក់ទំនង និងរៀបចំឯកសារ
- មានចំណង់ចំណូលចិត្តខ្ពស់ក្នុងការធ្វើការងារជាក្រុម និងអាចដោះស្រាយបញ្ហាបានល្អ
- មានចំណេះដឹងភាសាអង់គ្លេស និងអាចប្រើប្រាស់កុំព្យូទ័របានស្ទាត់ជំនាញ (Microsoft Office Word & Excel)

## របៀបដាក់ពាក្យ

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមអញ្ជើញផ្ញើប្រវត្តិរូបសង្ខេប (មានបិទរូបថត 4x6) ជាមួយលិខិតអមជាភាសាខ្មែរ/អង់គ្លេសមកធនាគារតាមរយៈ អ៊ីម៉ែល: hr@ftbbank.com ឬការិយាល័យកណ្តាល ស្ថិតនៅអគារលេខ ៣៣C-D ផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ ៧មករា រាជធានីភ្នំពេញ ឬតាមសាខាណាមួយ របស់ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ។

មានតែបេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងត្រូវបានជាប់ក្នុងបញ្ជីសម្រាំង និងត្រូវបានទូរសព្ទអញ្ជើញឲ្យមកចូលសម្ភាសន៍ ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់លេខទូរសព្ទ **០៨១ ៦៦៦ ៥៩៧/០៨១ ៦៦៦ ៥៣៥**

វិនិយោគដើម្បីអនាគត
Investing in the future

☎ : 023 862 111
E-mail: hr@ftbbank.com
www.ftbbank.com
f : www.facebook.com/ftbcambodia